**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**Kingdom of Cambodia**

Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

**Ministry of Industry, Mines and Energy**

លេខ: ៦៤០ ឧរថ.ឧតរ-ប្រក

រាជធានីភ្នំពេញ.ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០១០

# ប្រកាស

## ស្តីពី

## ប្រតិភូកម្មអំណាចនៃការងារឧស្សាហកម្ម ជូនដល់ថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ គោលដៅនៃការិយាល័យច្រកចេញ-ចូលតែមួយ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញប្រកាសលេខ ០៨៤ ឧរថ.ឧតស.ប្រក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីប្រតិភូកម្មអំណាចការងារឧស្សាហកម្ម ជូនដល់ស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង
- បានឃើញប្រកាសលេខ ៩២៧ ប្រក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃការិយាល័យប្រជាពលរដ្ឋ នៅក្រុង ស្រុក ខណ្ឌ គោលដៅ
- បានឃើញប្រកាសលេខ ៩២៨ ប្រក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃការិយាល័យច្រកចេញ-ចូលតែមួយ នៅក្រុង ស្រុក ខណ្ឌ គោលដៅ
- បានឃើញសេចក្តីកំណត់លេខ ០១ សកណ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ របស់គណៈកម្មាធិការជាតិសំរាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីរបៀបរបបធ្វើការងាររបស់ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង សំរាប់ជួយគាំទ្រដល់ការអនុវត្តគំរោងសាកល្បងការិយាល័យច្រកចេញ-ចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ។
- បានឃើញប្រកាសលេខ ៦០៧ ឧរថ.អឧ.ប្រកចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីនីតិវិធី និងបែបបទស្នើសុំបង្កើតរោងចក្រ-សិប្បកម្ម ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣

45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

# សម្រេច

**ប្រការ១ :** ធ្វើប្រតិភូកម្មអំណាចពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជូនដល់រដ្ឋបាលក្រុង ស្រុក និងខណ្ឌ គោលដៅនៃការិយាល័យច្រកចេញ-ចូលតែមួយ ដើម្បីអនុវត្តការចុះបញ្ជីសិប្បកម្ម ស្របតាមនីតិវិធី និងបែបបទ កំណត់ដោយប្រកាសលេខ ៦០៧ ឧរថ.អឧ.ប្រក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចំពោះសហគ្រាសសិប្បកម្មតម្រូវស្នើសុំចុះបញ្ជី ដែលមានទុនសមមូលសរុបតិចជាង ៥.០០០ USD ( ប្រាំពាន់ដុល្លារសហរដ្ឋអាមេរិក) ។

**ប្រការ២ :** សាលាក្រុង ស្រុក និងខណ្ឌគោលដៅ នៃការិយាល័យច្រកចេញ-ចូលតែមួយទាំងអស់ ត្រូវធ្វើការកំណត់ប្រភេទសិប្បកម្ម និងអនុវត្តការចុះបញ្ជីសិប្បកម្ម តាមគោលការណ៍ប្រតិភូកម្មអំណាចនេះ ដោយគោរពតាមនីតិវិធី និងគំរូបែបបទ ស្នើសុំបង្កើតសិប្បកម្ម ដូចមានចែងកំណត់ ក្នុងប្រកាសលេខ ៦០៧ ឧរថ.អឧ.ប្រក និងស្នើសុំការផ្តល់អត្តលេខអចិន្ត្រៃយ៍សំរាប់ការចុះបញ្ជីសហគ្រាស ពីមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣ :** សាលាក្រុង ស្រុក និងខណ្ឌគោលដៅ នៃការិយាល័យច្រកចេញ-ចូលតែមួយទាំងអស់ ត្រូវបញ្ជូនសំណុំឯកសារចុះបញ្ជីសិប្បកម្ម ក្រោយបានធ្វើការចុះបញ្ជីរួចភ្លាមមកមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីបញ្ចូនទិន្នន័យ ស្ថិតិ និងផ្តល់វិញ្ញាបនបត្រដំណើរការ ។

**ប្រការ៤ :** រាល់ការទទួលពាក្យសុំចុះបញ្ជី ការបង់កម្រៃសេវាទទួលពាក្យ និងកម្រៃសេវារដ្ឋបាលផ្សេងៗទៀត ត្រូវអនុវត្តនៅកន្លែងតែមួយ នៅការិយាល័យច្រកចេញ-ចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌគោលដៅ។ សាលាក្រុង ស្រុក និងខណ្ឌគោលដៅ ត្រូវផ្តល់របាយការណ៍ប្រចាំខែទៀងទាត់ អំពីការទទួលចុះបញ្ជីសហគ្រាស និងចំណូលសេវាកម្មផ្សេងៗ ពាក់ព័ន្ធនឹងការចុះបញ្ជីសហគ្រាសជូនមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលនៅរៀងរាល់សប្តាហ៍ទី១ នៃខែបន្ទាប់នីមួយៗ។

**ប្រការ៥ :** មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបញ្ជូនផ្សព្វផ្សាយសេចក្តីណែនាំអំពីលិខិត បទដ្ឋាន និងគំរូបែបបទផ្សេងៗទៀត ដែលក្រសួងបានកំណត់ពាក់ព័ន្ធនឹងការចុះបញ្ជីសិប្បកម្ម និងចាត់បញ្ចូនមន្ត្រីជំនួយការប្រតិភូកម្ម នៅការិយាល័យឧស្សាហកម្ម ប្រចាំក្រុង ស្រុក ខណ្ឌ ធ្វើជាសេនាធិការឱ្យអភិបាលក្រុង ស្រុក ខណ្ឌគោលដៅ ក្នុងការអនុវត្តប្រតិភូកម្មអំណាចនេះឱ្យមានប្រសិទ្ធភាព។

**ប្រការ៦ :** ប្រកាសលេខ ៨៤ ឧរថ.ឧតស.ប្រក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីប្រតិភូកម្មអំណាចនៃការងារឧស្សាហកម្ម ជូនដល់ស្រុកសៀមរាបនៃខេត្តសៀមរាប និងស្រុកបាត់ដំបងនៃខេត្តបាត់ដំបង របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវទុកជានិរាករណ៍។

**ប្រការ៧ :** ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រី**

ស៊ុយ_សែម

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលារាជធានី ខេត្ត របស់ក្រុង ស្រុក ខណ្ឌ គោលដៅនៃការិយាល័យច្រកចេញ-ចូលតែមួយ
- សាលាក្រុង ស្រុក ខណ្ឌ គោលដៅនៃការិយាល័យ ច្រកចេញ-ចូលតែមួយទាំងអស់
- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី ខេត្ត របស់ក្រុង ស្រុក ខណ្ឌ គោលដៅនៃការិយាល័យច្រកចេញ-ចូលតែមួយទាំងអស់
- ដូចប្រការ២ និង ៣ "**ដើម្បីអនុវត្ត**"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ០០.ស៊ី ...

រាជធានីភ្នំពេញ, ថ្ងៃទី.........ខែ.........ឆ្នាំ២០១០

## សេចក្តីណែនាំ

### ក្នុងការអនុវត្តន៍ប្រកាសលេខ ៦៤០ ឧរថ.អឧ.ប្រក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពី ប្រតិភូកម្មអំណាចនៃការងារឧស្សាហកម្ម

- ប្រកាសលេខ ៤២៧ ប្រក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១០ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃការិយាល័យប្រជាពលរដ្ឋ នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ។
- ប្រកាសលេខ ៤២៨ ប្រក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១០ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃការិយាល័យច្រកចេញ-ចូលតែមួយនៅក្រុង ស្រុក ខណ្ឌ គោលដៅ ។
- សេចក្តីកំណត់លេខ ០១ សកណ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពី របៀបរបបធ្វើការងាររបស់ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង សម្រាប់ជួយគាំទ្រដល់ការអនុវត្តន៍គម្រោងសាកល្បងការិយាល័យច្រកចេញ-ចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ។
- ប្រកាសលេខ ៦៤០ ឧរថ.អឧ.ប្រក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០១០ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពី ប្រតិភូកម្មអំណាចនៃការងារឧស្សាហកម្ម ជូនដល់ក្រុង ស្រុក ខណ្ឌ គោលដៅ ។

ការធ្វើប្រតិភូកម្មអំណាចនៃការងារឧស្សាហកម្ម ជូនដល់ក្រុង ស្រុក ខណ្ឌគោលដៅនេះ គឺមានគោលបំណង:

- កែលំអឱ្យកាន់តែប្រសើរឡើងនូវការផ្តល់សេវាតាមរយៈច្រកចេញ-ចូលតែមួយដើម្បីឆ្លើយតបទៅនឹងសំណូមពររបស់ប្រជាពលរដ្ឋ ពាណិជ្ជករ និង សហគ្រិន ទាំងឡាយ ។
- បង្វិតសេវាសាធារណៈឱ្យកាន់តែជិតប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយជាអតិបរិមានូវពេលវេលា និងការចំណាយ រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

- បង្កើនប្រសិទ្ធិភាពការងាររបស់មន្ត្រីភ្នាក់ងារមានសមត្ថកិច្ចប្រចាំការិយាល័យច្រកចេញ-ចូលតែមួយ តាមគោលការណ៍អភិបាលកិច្ចល្អ ដែលជាទិសដៅចំបងរបស់រាជរដ្ឋាភិបាល ។
- សំណូមពរមន្ត្រីភ្នាក់ងារមានសមត្ថកិច្ចទទួលបន្ទុកការងារសេវាធិការឱ្យប្រតិភូកម្ម ត្រូវយកចិត្តទុកដាក់បំពេញការងារជូនប្រជាពលរដ្ឋ ដែលសុំច្បាប់អនុញ្ញាតដោយស្មារតីទទួលខុសត្រូវសំដៅឱ្យការផ្តល់សេវានេះ ប្រព្រឹត្តទៅបានល្អ ។
- បង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ផលិតករបង្កើតសហគ្រាសសិប្បកម្ម ក្នុងការយល់ដឹងនូវសារៈសំខាន់នៃការសុំចុះបញ្ជី និងយល់នូវសេចក្តីណែនាំដែលពាក់ព័ន្ធដល់ការអនុញ្ញាតនេះ ។

## I - ទំរង់បែបបទសុំចុះបញ្ជីសហគ្រាសសិប្បកម្ម

ប្រជាពលរដ្ឋ ផលិតករ ដែលមានបំណងចង់បង្កើតមូលដ្ឋានសហគ្រាសសិប្បកម្ម នៅក្នុង ក្រុង ស្រុក ខណ្ឌគោលដៅ ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម:

**១- ប្រជាពលរដ្ឋ ផលិតករ ត្រូវមានមកជាមួយនូវ:**

ក-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ រឺ ប័ណ្ណស្នាក់នៅ រឺ ប័ណ្ណគ្រួសារថតចំលង រឺក៏លិខិតបញ្ជាក់អំពីការស្នាក់នៅពិតប្រាកដ ចេញដោយអាជ្ញាធរមូលដ្ឋាន ចំនួន ០១ ច្បាប់ ។

ខ-រូបថត ៤ គុណ ៦ ចំនួន ២ សន្លឹក ។

គ-សេចក្តីជូនដំណឹងអំពីការសុំចុះបញ្ជីសហគ្រាសសិប្បកម្មនៅក្នុងមូលដ្ឋាន ដើម្បីឱ្យប្រជា-ពលរដ្ឋនៅជុំវិញមូលដ្ឋានផលិតកម្មបានដឹងជាមុន ដោយការបិទផ្សាយសេចក្តីជូនដំណឹងនេះនៅកន្លែងមូលដ្ឋានផលិតកម្ម និងសាលាឃុំ ក្រោយរយៈពេល ១៥ថ្ងៃ ។

ករណីមានការជំទាស់តវ៉ាណាមួយពីសំណាក់ប្រជាពលរដ្ឋរស់នៅជិតខាងចំពោះការបង្កើតមូលដ្ឋានសហគ្រាសសិប្បកម្មដោយប្រការណាមួយ មិនមែនជារឿងបច្ចេកទេស គូភាគីទំនាស់ទាំងឡាយមានរយៈពេល១៥ថ្ងៃ សម្រាប់ដោះស្រាយទំនាស់ទាំងនោះឱ្យបានចប់រួចរាល់ ។ បើការដោះស្រាយនេះមិនបានទទួលលទ្ធផលទេ អភិបាលស្រុកមានសិទ្ធិអំណាចពេញលេញក្នុងការសំរេចកិច្ចការនេះ ។

**២-ប្រជាពលរដ្ឋ ផលិតករ ត្រូវបំពេញទំរង់បែបបទនៃការសុំចុះបញ្ជីមូលដ្ឋានសហគ្រាសសិប្បកម្មនៅការិយាល័យច្រកចេញ-ចូលតែមួយ តាមទំរង់បែបបទដូចខាងក្រោម:**

ក- ពាក្យសុំចុះបញ្ជីសហគ្រាសសិប្បកម្ម ចំនួន ០១ ច្បាប់ ដោយមានបិទរូបថត ៤ គុណ ៦ ។

ឌ-របាយការណ៍សេដ្ឋកិច្ច ចំនួន ០១ ច្បាប់ ។

ចំពោះរបាយការណ៍សេដ្ឋកិច្ច ម្ចាស់មូលដ្ឋានសហគ្រាសសិប្បកម្ម ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ទៅតាមសភាពជាក់ស្តែងនូវប្រភេទផលិតកម្មរបស់ខ្លួន អំពីចំនួនទុនសរុប ចំនួនពលករបំរើការងារជាអចិន្ត្រៃយ៍ ទព្វសម្ភារៈ វត្ថុធាតុដើម គ្រឿងចក្រ-គ្រឿងម៉ាស៊ីន មធ្យោបាយដឹកជញ្ជូន ទីតាំង អាគារ ឃ្លាំង សំរាប់បំរើឱ្យផលិតកម្ម ។ តំលៃចលនៈវត្ថុ និង អចលនៈវត្ថុ ត្រូវគិតតាមតំលៃបច្ចុប្បន្ន នាពេលដែលសុំការចុះបញ្ជីនេះ ។

ត- បញ្ជីភាគហ៊ុន ចំនួន ០១ ច្បាប់ (បើមាន) ។

ចំពោះបញ្ជីភាគហ៊ុន ម្ចាស់មូលដ្ឋានសហគ្រាសសិប្បកម្មត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីចំនួនសមាជិកភាគហ៊ុនដែលចូលរួមក្នុងមុខរបរផលិតកម្មរបស់ខ្លួន ។

ករណីមិនយល់ច្បាស់ក្នុងការបំពេញពាក្យសុំចុះបញ្ជីសហគ្រាសសិប្បកម្មនេះ ប្រជាពលរដ្ឋ ផលិតករ អាចសួរពត៌មានច្បាស់លាស់បន្ថែម នៅការិយាល័យច្រកចេញ-ចូលតែមួយ រឺ អាចស្នើ សុំជំនួយពីការិយាល័យនេះ ដើម្បីបំពេញពាក្យសុំនេះឱ្យបានត្រឹមត្រូវ ។ បើការិយាល័យច្រកចេញ-ចូលតែមួយ ពុំមានលទ្ធភាពពន្យល់ទេ អាចបញ្ជូនអ្នកដាក់ពាក្យសុំ ទៅជួបមន្ត្រីជំនាញរបស់ការិយាល័យកិច្ចការឧស្សាហកម្មប្រចាំការនៅទីនោះ ដើម្បីពន្យល់បន្ថែមទៀត ។ ពាក្យស្នើសុំចុះបញ្ជីមានដាក់លក់នៅការិយាល័យច្រកចេញ-ចូលតែមួយ ។

## II - ដំណើរការនៃការដាក់ពាក្យសុំចុះបញ្ជី

ម្ចាស់សហគ្រាសសិប្បកម្ម ត្រូវដាក់ពាក្យសុំចុះបញ្ជីនៅការិយាល័យច្រកចេញ-ចូលតែមួយ បន្ទាប់ពីបានបំពេញត្រឹមត្រូវទៅតាមបែបបទ ដែលបានបរិយាយក្នុងចំណុច I រួចមក ។

- ការិយាល័យជួរមុខមានភារកិច្ចទទួលយក និង ពិនិត្យសំណុំលិខិតនោះ រួចចុះលេខចូល ដោយបញ្ជាក់ម៉ោង ថ្ងៃ ខែ ឆ្នាំ និង ចេញបង្កាន់ដៃបញ្ជាក់ថា បានដាក់ពាក្យចុះបញ្ជី និង បង្កាន់ដៃបានបង់សេវាកម្មរួចជូនដល់អតិថិជន ហើយត្រូវបញ្ជូនឯកសារនេះ ដោយភ្ជាប់ជាមួយ បង្កាន់ដៃសេវាកម្មទៅការិយាល័យជួរក្រោយ គឺការិយាល័យឧស្សាហកម្ម រ៉ែ និងថាមពល ។
- ការិយាល័យឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវប្រថាប់ត្រាចូលលើពាក្យសុំ ដោយបញ្ជាក់ ម៉ោង ថ្ងៃខែ ឆ្នាំ និងធ្វើការចុះពិនិត្យមូលដ្ឋានផលិត (ក្នុងករណីចាំបាច់) ព្រមទាំងធ្វើ កំណត់បង្ហាញច្បាស់លាស់ រួចដាក់ជូនអភិបាលក្រុង ស្រុក ខណ្ឌគោលដៅ ពិនិត្យ និង សំរេច ។ រយៈពេលនៃការសំរេចចិត្តរបស់ការិយាល័យនេះ គឺមិនឱ្យលើសពី បីថ្ងៃ (ថ្ងៃការងារ) ។
- ការចុះបញ្ជីនេះមានសុពលភាពរហូត លើកលែងតែមានការកែប្រែខ្សែសង្វាក់ផលិតកម្ម បន្ថែមមុខផលិតផល ប្តូរទីតាំង ឬផ្លាស់ប្តូរម្ចាស់សហគ្រាសសិប្បកម្ម ត្រូវធ្វើការស្នើសុំចុះបញ្ជីជាថ្មី ។

III – លក្ខខណ្ឌនៃការចុះបញ្ជី:

ចំពោះការចុះបញ្ជីសហគ្រាសសិប្បកម្ម ត្រូវបានកំណត់ចំពោះតែមូលដ្ឋានផលិតកម្ម ដែលស្ថិត នៅក្នុងក្រុង ស្រុក ខណ្ឌគោលដៅតែប៉ុណ្ណោះ ។

- សាលាក្រុង ស្រុក ខណ្ឌគោលដៅត្រូវធ្វើការកំណត់ប្រភេទសហគ្រាសសិប្បកម្ម និងអនុវត្ត ការចុះបញ្ជីដោយគោរពតាមនីតិវិធី និងគំរូបែបបទស្នើសុំបង្កើតសហគ្រាសសិប្បកម្ម ដូចមាន ចែងកំណត់ក្នុងប្រកាសលេខ ៦០៧ ឧរថ.អឧ.ប្រក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១០ និង ស្នើសុំការផ្តល់អត្តលេខអចិន្ត្រៃយ៍សម្រាប់ការចុះបញ្ជីសហគ្រាសសិប្បកម្មពីមន្ទីឧស្សាហកម្ម រ៉ែ និងថាមពល ។

- ការិយាល័យច្រកចេញ-ចូលតែមួយនៃក្រុង ស្រុក ខណ្ឌគោលដៅទាំងអស់ ត្រូវបញ្ជូនសំណុំ ឯកសារចុះបញ្ជីសហគ្រាសសិប្បកម្ម ក្រោយពីបានធ្វើការចុះបញ្ជីរួចភ្លាម មកមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីបញ្ចូលទិន្នន័យ ស្ថិតិ និងផ្តល់វិញ្ញាបនបត្រដំណើរការ ។

IV - កំរៃសេវាកម្ម:

កំរៃសេវាកម្ម ដែលត្រូវចំណាយដោយម្ចាស់សហគ្រាសសិប្បកម្ម ក្នុងការសុំចុះបញ្ជី សហគ្រាសសិប្បកម្ម ត្រូវបានកំណត់ដូចមានចែង ក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំនេះ ។

V - អំពីដំណើរការងាររបស់ភ្នាក់ងារមានសមត្ថកិច្ចប្រចាំក្រុង ស្រុក ខណ្ឌគោលដៅ:

ភ្នាក់ងារមានសមត្ថកិច្ច ដែលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចាត់តាំងឱ្យប្រចាំ ការនៅការិយាល័យច្រកចេញ-ចូលតែមួយ ក្នុងក្រុង ស្រុក ខណ្ឌគោលដៅ ត្រូវបំពេញការងារ ឱ្យបានសុក្រិត្យ និងមានប្រសិទ្ធិភាពខ្ពស់បំផុត ព្រមទាំងធ្វើការពន្យល់ណែនាំដល់ប្រជាពលរដ្ឋ ឧស្សាហករ សិប្បករ ឱ្យយល់ច្បាស់ពីបញ្ហានានា ដែលពាក់ព័ន្ធដល់ការគ្រប់គ្រងវិស័យ ឧស្សាហកម្ម-សិប្បកម្មនេះ ព្រមទាំងជួយសម្រួល និងបង្កើនទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ ផលិតករ ។ ហាមមន្ត្រីមានសមត្ថកិច្ចប្រចាំការនៅការិយាល័យឧស្សាហកម្មក្រុង ស្រុក ខណ្ឌគោលដៅ បង្កការលំបាកដល់ឧស្សាហករ-សិប្បករ ឬ ប្រជាពលរដ្ឋ ។ ការជូនប្រាក់ សគុណ ឬ មធ្យោបាយផ្សេងៗ ដែលពាក់ព័ន្ធដល់ការចុះបញ្ជីនេះ ត្រូវហាមឃាត់ជាដាច់ខាត ។ ក្រសួងនឹងធ្វើការអង្កេតតាមដាន លើសកម្មភាពអនុវត្តរបស់មន្ត្រីភ្នាក់ងារមានសមត្ថកិច្ច ដែល ក្រសួងបានចាត់តាំងឱ្យប្រតិបត្តិការងារ នៅក្នុងការិយាល័យច្រកចេញ-ចូលតែមួយនេះ ។ ក្រសួងនឹងចាត់វិធានការណ៍ចំពោះមន្ត្រីប្រព្រឹត្តល្មើស ស្របតាមការកំណត់នៃច្បាប់សហលក្ខន្តិកៈ

ឞ ឨ

មន្ត្រីរាជការស៊ីវិល និង អនុក្រឹត្យ ស្តីពី ការដាក់ពិន័យមន្ត្រីរាជការ ទៅតាមទោសកំហុសដែលខ្លួនបានប្រព្រឹត្តិ ។

ទទួលបានសេចក្តីណែនាំនេះ មន្ត្រីមានសមត្ថកិច្ចប្រចាំការិយាល័យច្រកចេញ-ចូលតែមួយក្នុងក្រុង ស្រុក ខណ្ឌគោលដៅ និងប្រជាពលរដ្ឋ ផលិតករ ដែលមានបំណង ចង់បង្កើតមូលដ្ឋានសហគ្រាសសិប្បកម្ម ក្នុងក្រុង ស្រុក ខណ្ឌគោលដៅ ទាំងអស់ ត្រូវអនុវត្តទៅតាមខ្លឹមសារនៃប្រកាស និង សេចក្តីណែនាំនេះ ឱ្យត្រឹមត្រូវ និង មានប្រសិទ្ធិភាពខ្ពស់ ។៚

រាជធានីភ្នំពេញ. ថ្ងៃទី ខែ ឆ្នាំ ២០១០

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

ស៊ុយ សែម

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
  "ដើម្បីជូនជ្រាប"
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  "ដើម្បីសំរបសំរួល និង សហការ"
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់សាលាក្រុង ស្រុក ខណ្ឌគោលដៅ
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និង
  "ដើម្បីសហការ និង មុខការ"
- ឯកសារ-កាលប្បវត្តិ